ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខ ០៤៥៤ គ.ជ.អ.ប

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦

**គោរពជូន**
**ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ**
**និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ**

**កម្មវត្ថុ:** សំណើសុំថវិកាចំនួន ២០,០០០,០០០.០០ រៀល ដើម្បីរៀបចំកិច្ចប្រជុំលើកទី១២ របស់ គ.ជ.អ.ប ។

**យោង:** ចំណារឯកភាពរបស់**សម្តេចក្រឡាហោម** លើលិខិតរបស់លេខាធិការដ្ឋាន គ.ជ.អ.ប ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៦ ស្តីពីសំណើសុំគោលការណ៍អនុញ្ញាតរៀបចំកិច្ចប្រជុំលើកទី១២ របស់ គ.ជ.អ.ប ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមអគ្គនាយកជ្រាបថា គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ នឹងរៀបចំកិច្ចប្រជុំលើកទី១២ របស់ខ្លួន នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ខាងមុខនេះ នៅសាលប្រជុំរបស់ក្រសួងមហាផ្ទៃ ដើម្បីពិភាក្សាលើប្រធានបទសំខាន់ៗដូចមានក្នុងកម្មវិធីភ្ជាប់មកជាមួយ ។

ផ្អែកលើផែនការអនុវត្តរយៈពេលបីឆ្នាំ ដំណាក់កាលទីពីរ ដែលបានឯកភាពជាមួយដៃគូអភិវឌ្ឍន៍ ហើយដែលបានអនុម័តដោយ គ.ជ.អ.ប បានកំណត់ថា រាល់ការចំណាយលើកិច្ចប្រជុំកម្រិតនយោបាយនានា ស្តីពីកំណែទម្រង់នឹងត្រូវរ៉ាប់រងដោយថវិការបស់រាជរដ្ឋាភិបាល។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប ស្នើសុំថវិកាចំនួន ២០,០០០,០០០.០០ រៀល (ម្ភៃលានរៀលគត់) របស់ក្រសួងមហាផ្ទៃ ដើម្បីប្រើប្រាស់ក្នុងការចំណាយលើការរៀបចំកិច្ចប្រជុំលើកទី១២ របស់ គ.ជ.អ.ប ខាងលើនេះ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាពិនិត្យ និងសម្រេចតាមការគួរ ។

សូមជូនភ្ជាប់ជាមួយនូវបញ្ជីប៉ាន់ស្មានការចំណាយលើកិច្ចប្រជុំលើកទី១២ របស់ គ.ជ.អ.ប ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**